# ការសំភាសន៍របស់លោកពូ យ៉េម ពៅ

**អ្នកដែលសំភាសន៍ឈ្មោះ ញ៉ៀម សុគន្ធា     អ្នកដែលត្រូវគេសំភាសន៍ឈ្មោះយ៉េម ពៅ**

## សង្ខេបរបស់លោកពូ យ៉េម ពៅ

លោកពូ យ៉េម ពៅជាអ្នកកើតនៅក្នុងភូមិដំរីស្លាប់តែឥឡូវគេដូរដាក់ភូមិថ្មី ដែលនៅស្រុកស្អាង គាត់មានបងប្អូន៣នាក់ហើយបងប្រុសម្នាក់បានស្លាប់ដោយសារជិះម៉ូតូបុកគោ ហើយបងស្រីមួយទៀតគឺពុំបានយកប្ដីទេហើយមានចរិកដូចជាប្រុស។ ឪពុកម្ដាយជាអ្នកដែលធ្វើចំការហើយឪពុកក៏ជាអ្នកកាប់គោដែរ។ លោកពូបានធ្លាប់ទៅធ្វើការនៅប្រទេសថៃផងដែរតែដោយសារត្រូវប៉ូលីសដេញចាប់ទើបគាត់ត្រលប់មកស្រុកកំនើតវិញ។

កៈ ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់លោកពូអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិរបស់លោកពូនាងខ្ញុំឈ្មោះញ៉ៀម សុគន្ធាជាអ្នកសំភាសន៍អំពីជីវិតរបស់លោកពូនៅក្នុងថ្ងៃនេះហើយពួកយើងសំភាសន៍នៅក្នុងខែមិនាឆ្នាំ២០១៨ ការសំភាសន៍មានទីតាំងស្ថិតនៅក្នុងភូមិព្រែកហូរខាងលិច សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល ប្រទេសកម្ពុជា។អញ្ចឹងញ៉ុមសូមសំភាសន៍អំពីជីវិតរបស់លោកពូដូចតទៅ អញ្ចឹងលោកពូសូមប្រាប់ឈ្មោះពេញលោកពុឈ្មោះអីគេដែរ?

ខៈ ញ៉ូមយ៉េម ពៅ។

កៈ ចាំសព្វថ្ងៃលោកពូអាយុប៉ុន្មានហើយ?

ខៈ ៤៨។

កៈ ៤៨ឆ្នាំម៉ងហោ?

ខៈ បាទ!!

កៈ លោកពូក្រៅពីឈ្មោះពេញលោកពូមានឈ្មោះអីផ្សេងទៀតទេ?

ខ៖ អត់ទេ ឈ្មោះតែមួយ។

ក៖ ចុះពេលនៅពីក្មេងម៉ែមានដាក់ឈ្មោះអីអោយអីអត់?

ខ៖ អត់ ហៅតែឈ្មោះមួយហ្នឹងម៉ង។

ក៖ ហៅតែពីមួយហ្នឹងទេហេ!!អត់មានហៅឈ្មោះអីផ្សេងទៀតទេហេ?

ខ៖ បាទ!!

ក៖ លោកពូឆ្នាំខ្មែរកើតសត្វអីគេវិញ?

ខ៖ សត្វហ្ហ៎?

ក៖ ចាំ!!

ខ៖ សត្វ!!

ក៖ ដូចឆ្នាំជូតឆ្លូវខាលថោះអីវ៉ាន់ហ្នឹងហ្ហ៎?

ខ៖ ហ្ហ៎អាឆ្នាំយើងឆ្នាំចឆ្នាំអីហ្នឹងហេ?

ក៖ ចាំ!!

ខ៖ និយាយញ៉ុមកើតឆ្នាំ!!និយាយតែខ្លួនញ៉ុមម៉ងហេ?

ក៖ ចាំ!!

ខ៖ ញ៉ុមកើតឆ្នាំជ្រូក!!

ក៖ ជ្រូកហេ?

ខ៖ បាទ!!

ក៖ ឆ្នាំកុល!!បើសួរពូឆ្លើយប្រពន្ធម៉េចកើត!!

ខ៖ បាទ!!

ក៖ អញ្ចឹងពូសំរាប់លោកពូមានបងប្អូនប្រុសស្រីប៉ុន្មាននាក់ដែរ?

ខ៖ ញ៉ុមមាន៣នាក់ប៉ុន្តែស្លាប់ម្នាក់ហើយ!!

ក៖ គាត់ស្លាប់មូលហេតុអីគេដែរ?

ខ៖ គាត់ជិះម៉ូតូបុកគោ!!និយាយអោយត្រង់ម៉ង នៅសល់២នាក់។

ក៖ ហើយគាត់ស្រវឹងហីអីបានគាត់ជិះម៉ូតូបុកគោ?

ខ៖ អត់ទេ គាត់អត់ស្រវឹងផង កាលជំនាន់ហ្នឹងវាទឹមតែបែកចេញមកហ្ម៉ូម៉ូតូមួយៗគាត់ទៅរៀនជិះ។

ក៖ ហ្ហ៎!!

ខ៖ គាត់អត់ហ៊ានស្រវឹងផង ។

ក៖ ហ្ហ៎អ៊ីចឹងដោយសារទឹមតែរៀនជិះម៉ូតូ ជិះទៅបុកគោអានិតគាត់ណាស់ពូដល់ពេលអាណិតគាត់ណាស់ណោះចង់រៀនជិះម៉ូតូអ៊ីចឹងសោះទៅជិះបុកគោ!!

ខ៖ បាទ!!

ក៖ ស្លាប់វិញទៅ!!

ខ៖ គាត់ទឹមតែរៀនជិះទឹមតែទិញម៉ូតូរៀនជិះបុកគោងាប់បណ្តោយ!!

ក៖ គាត់ស្លាប់អាយុប៉ុន្មានដែរពូ?

ខ៖ អាយុ៥០គត់។

ក៖ ហ្ហ៎!!

ខ៖ បងញ៉ុមហា៎!!

ក៖ ចា៎!!

ខ៖ ហ្នឹង!!

កៈ ហ្នឹងហើយ!!ហើយគាត់ស្លាប់ពេលឆ្នាំណាវិញពូ?

ខៈ ហេ៨០គត់ ឥឡូវមិនដឹងប៉ុន្មានទេនេះ!!ពីអាយុ៨០គត់ឥឡូវ គាត់ប្រហែលជា២០ឆ្នាំហើយគាត់ស្លាប់ហ្នុំ!!

កៈ ហ្នុំអញ្ចឹងបែកហើយភ្លាម ?

ខៈ បាទ!!បែកហើយភ្លាម។

កៈ ជំនាន់៨០ជាងពូណោះ?

ខៈ បាទ!!

កៈ ចុះបងប្អូនពូ៣នាក់ហ្នឹងពូកូនទីប៉ុន្មានវិញ?

ខៈ ញុំមពៅគេម៉ង!!

កៈ ពៅគេអាយុ៥៨ហើយ!!

ខៈ បាទ!!

កៈ ពូសំរាប់៣នាក់ហ្នឹងគេឈ្មោះអីគេខ្លះទាំងពូទាំងអី?

ខៈ មួយឈ្មោះយ៉ែម សំបុកអាហ្នឹងបងគេហា់!!

កៈ ចា់ដែលស្លាប់ទៅហ្នឹង!!

ខៈ បាទហ្នឹងហើយ!ទីពីរឈ្មោះយ៉ែម ខុប!

កៈ កុប?

ខៈ បាទ!! កៈ ចា់!!

ខៈ តែ៣ហ្នឹងហិញុំមពៅគេហិយ៉ែម ពៅហ្នឹងម៉ងហេ?

កៈ ភាគច្រើនខ្មែរយើងតែពៅគេដាក់ឈ្មោះច្រើនហៅតែពៅ!!

ខ៖ បាទ!!

ក៖ បើមិនអ៊ីចឹងក៏ហៅស្រីពៅ បើឈ្មោះហ្នឹងអត់ពិតក៏ហៅពៅដែរអោយតែពៅគេ ភាគច្រើនខ្មែរយើងតែអ៊ីចឹង!!ពូអនុស្សាវរីយ៍ដែលពូមានជាមួយបងប្អូនហាំមានអីគេខ្លះវិញពូអាចរៀបរាប់ពីការចងចាំដែលពូមានជាមួយបងប្អូនពេលដែលមិនទាន់មានប្រពន្ធអ៊ីចឹងណាស់?

ខ៖ ពីប្រវត្តិជាមួយបងប្អូន?

ក៖ ចាំ!!

ខ៖ បងប្អូនចេះតែស្រលាញ់គ្នាហើយអត់មានថាបែកបាក់គ្នាអីទៅដល់ស្រុកណាមិត្តតែរកបងប្អូន!!

ក៖ ចាំ!!

ខ៖ អត់មានដែលស្អប់ខ្ពើមរអើមអីបងប្អូនឡើយ!!

ក៖ តែពួកគាត់ឥឡូវពួកគាត់នៅឯណាខ្លះពូ?

ខ៖ គាត់នៅហ្នឹងស្អាងយើងព្រែកតូចហ្នឹងនេះ!!

ក៖ អ៊ីចឹងពេលពូមួយដែលស្លាប់ហ្នឹងគាត់នៅឯណាវិញ?

ខ៖ នៅហ្នឹងព្រែកតូចដែរ។

ក៖ នៅហ្នឹងព្រែកតូចហ្នឹងដែរ!!

ខ៖ បាទនៅនឹងព្រែកតូច។

ក៖ ហើយអ្នកដែលនៅរស់ក៏នៅហ្នឹងព្រែកតូចដែរ?

ខ៖ បាទ!!មកនៅតែខ្ញុំនៅហ្នឹងព្រែកហូរហ្នឹងនេះ!!

ក៖ ចាំពូមកនៅព្រែកហូរប៉ុន្មានឆ្នាំហើយ?

ខ៖ ទឹមមកនៅទឹមប្រហែលជាមួយឆ្នាំនេះ!!

កៈ ហ្នំទឹមមកនៅទេអ៊ីចឹង?

ខៈ ចា៎!!

កៈ អ៊ិចឹងពីមុនមកពូនៅព្រៃកគួចទេអ៊ីចឹងហេ?

ខៈ ញ៉ុមពីមុនមកញ៉ុមមកនៅរកស៊ីនៅតាខ្មៅ!

កៈ ចា៎!!

ខៈ ដល់នេះយើងផ្ទះជួលគេថ្លៃពេក!!

កៈ ហ៊ឺៗ!!

ខៈ ផ្ទះសុទ្ធតែ១០០អីណោះយើងរត់ម៉េចរួច។

កៈ ហ្នឹងហើយ!!

ខៈ ម្លោះហើយញ៉ុមមកនៅជួលនៅនេះអ៊ិចឹង

កៈ នៅនេះផ្ទះជួលទេពូហេ?

ខៈ ផ្ទះ ជួលតើ!!

កៈ ចា៎!!មួយខែប៉ុន្មានពូនៅនេះ?

ខៈ នេះ៥០០០០។

កៈ ផ្ទះនៅតែប៉ុន នេះហ្នឹងហី?

ខៈ ទាំងអស់ហ្នឹង!!

កៈ ថោកម្ល៉េះ?

ខៈ អានេះញ៉ុមតធ្វើខ្លួនឯង។

កៈ គេជួលអោយតែដីតើពូហេ?

ខ៖ បាទ!!

ក៖ ហើយដល់ពេលធ្វើផ្ទះពូធ្វើដោយខ្លួនឯងឬក៏យ៉ាងម៉េច?

ខ៖ អាខាងណោះញ៉ុមជួលខ្លួនឯងអានេះផ្ទះគេ!!

ក៖ ហ្ហ៎តែដល់ពេលយើងធ្វើផ្ទះអញ្ចឹងគេអត់ថាអីដែរពូហោ?

ខ៖ គេអត់អោយយើងធ្វើ!!

ក៖ ចឺ?? តែពូធ្វើបាន?

ខ៖ បាទ!!

ក៖ ហើយដល់ពេលអញ្ចឹងគេថាម៉េចទៅអ៊ីចឹង អត់អីទេហោ?

ខ៖ អត់មានថាអីគេអោយតែយើងធ្វើតើ!!

ក៖ ហ្ហ៎ហ្នឹងហើយ គេចិត្តល្អដែរតើពូហោ?

ខ៖ បាទ អោយតែយើងមានលទ្ធិភាព ពេលយើងចេញទៅយើងរូសវាចេញទៅយើងរូសយក របស់យើងទៅបើយកមិនបានយើងរូសចោលនៅហ្នឹងទៅ!!

ក៖ ចា៎តែម្ចាស់ដីហ្នឹងផ្ទះគេនៅណាវិញពូ?

ខ៖ គាត់ចាក់អង្រែហ្ហ៎!!

ក៖ ហ្ហ៎អ៊ីចឹងគាត់ចិត្តល្អដែរហ្នឹងអញ្ចឹង!!!ដីនេះមានប្លង់មានអីដែរពូហោ?

ខ៖ ទេអត់ដឹងដែរ!!អត់ដឹង។

ក៖ ដោយសារពេលនៅហ្នឹងពេលមុនមិនមែនដីអញ្ចឹងទេណាស់វាព្រៃកហ្នឹង។

ខ៖ នេះវាប្រហែលជាអត់ប្លង់ទេតាមមើល !! ញ៉ុមអត់ដឹងដែរ!!

ក៖ ពេលមុនពូនៅហ្នឹងមិនមែនដីទេណាស់ពូសុទ្ធតែព្រៃកទាំងអស់ពេលញ៉ុមនៅពីក្មេងញ៉ុម មកបេះត្រកួនអោយជ្រូកអីវ៉ាន់នៅនេះអញ្ចឹងហ៎!!

ខ៖ ហ្នឹង!!

ក៖ ហ្នឹងហើយ!!

ខ៖ ហ្នឹងពេលជំនាន់មុនញ៉ុមមកញ៉ុមឃើញព្រៃកដែរ ញ៉ុមដើរឆ្លងកាត់តាមហ្នឹងដែរ។

ក៖ ចាំ!!តាមពិតព្រៃកតូចបើជិះពីនេះទៅក៏វាមិនឆ្ងាយអីណាប៉ុន្មានដែរពូណោះ?

ខ៖ ដីប្រហែលជា១០គីឡូ។

ក៖ ហ្នឹងហើយ។

ខ៖ បើយើងទៅផ្លូវធំនេះ!!!

ក៖ ពូបងប្អូនពូគាត់រកស៊ីអីគេដែរ?

ខ៖ ធ្វើការរោងចក្រ។

ក៖ សុទ្ធតែអ្នកធ្វើការរោងចក្រ?

ខ៖ បាទ?

ក៖ កាត់ដេរឬក៏អីគេវិញ?

ខ៖ ដេរ កាត់ដេរ។

ក៖ ប្រុសៗហ្នឹង?

ខ៖ ស្រី!!នៅស្រីមួយ!!

ក៖ ហ្ន៎អ៊ីចឹងនៅស្រីប៉ុន្មានប្រុសប៉ុន្មានពូ។

ខ៖ ស្រីតែមួយប្រុសពីរ។

ក៖ ហ្ន៎ស្រីកណ្ដាលគេហោ?

ខ៖ បាទ!!

កៈ ឥឡូវគាត់មានគ្រួសារហើយពូហោ?

ខៈ នៅទេ!!

កៈ ហ៊ឺ??

ខៈ គាត់អត់យកប្តីផងដូចមនុស្សប្រុសអ៊ីចឹង។

កៈ អញ្ចឹង៥០ជាងហើយណាស់។

ខៈ បាទ៥០ជាងហើយ!!

កៈ បង ដោយសារបងពូ!!ហើយពូថីបានគាត់អត់យកប្តីយកអីអញ្ចឹង?

ខៈ ដឹងអីរឿងគេអាណាដឹង រឿងប្រវត្តិគេអាណាដឹង អាណាដឹងឥឡូវ!!

កៈ ហ៊ឺបងគេខ្លះដឹងហើយណាស់។

ខៈ ប្រវត្តិគេញុំមអត់ដឹងទេ។

កៈ តែគាត់ចរិកប្រុស?

ខៈ ចរិកប្រុសហាំ!!

កៈ ហ៊ឺចឹអញ្ចឹងបានអញ្ចឹង។

ខៈ ធ្វើការខ្លាំងជាងប្រុសទៀត ព្យូរដីព្យូរអីខ្លាំងជាងប្រុសទៀត!!

កៈ ចំសាហាវ?

ខៈ បាទ!!

កៈ ហោពូព្យូរដីមានសាហាវអីណា!!នឹមគោអីវ៉ាន់ហ្នូំ!!

ខៈ ហ្នឹង ព្យូរគោហ្នឹងពីជំនាន់ហ្នឹងយើងប្រើតែគោតើ យើងមានប្រើអាគោយន្តណា!!មានទាន់ចេញអាគោយន្តណាទឹមយើងឥឡូវចេញអាគោយន្តហ្នឹង។

កៈ ចាខ្លាំងរបស់គាត់មែន!!គាត់ឥឡូវសព្វថ្ងៃគាត់នៅជាមួយអ្នកណាគេវិញលោកពូ?

ខៈ នៅជាមួយម្តាយឪពុក។

កៈ ហ្នូអញ្ចឹងម្តាយឪពុកនៅរស់ទាំងពីរ?

ខៈ បាទ!!

កៈ ពូពេលនៅពីក្មេងពូចូលចិត្តលេងអីគេជាងគេជាមួយបងប្អូនជាងគេ?

ខៈ មានចូលចិត្តលេងអីមានចូលចិត្តតែឃ្វាលគោហ្នឹង ។

កៈ អញ្ចឹងភាគច្រើនទៅឃ្វាលគោហ្នឹងទាំងបងទាំងប្អូនហ្នឹងពូហេ?

ខៈ បាទហ្នឹងហើយ!!

កៈ ហ្នូហ្នឹងហើយ តែសប្បាយណាស់នៅពីក្មេងៗមិនមែនដូចសម័យឥឡូវទេ!!ដូចក្មេងៗនៅនេះវិញសប្បាយណាស់ ដល់ពេលឥឡូវវិញសោះកក្រោះម៉េចមិនដឹងទេ!!ក្មេងៗឥឡូវមិនមែនដូចក្មេងៗជំនាន់មុនទេ!!អញ្ចឹងពូចូលដល់អើរ!ពុកើតនៅក្នុងថ្ងៃខែឆ្នាំណាដែរ ឆ្នាំប៉ុន្មានពូកើត?

ខៈ ឥឡូវយើងគិត គិតទៅ យើងឆ្នាំកុលយើងអត់បានយកសំបុត្រកំណើតមកយើងអត់សូវចាំដែរអាហ្នឹង!!

កៈ អឺចឹងពូឆ្នាំ២០១៨ពូអាយុ៥៨ឆ្នាំ !!

ខៈ បាទ!!

កៈ អ៊ិចឹងគិតតាមហ្នឹង!!

ខៈ ហ្នឹងហើយយើងគិតទៅ។

កៈ ដោយសារពូ!!

ខៈ ដល់តែយើងយកសំបុត្រកំណើតមកបានយើងដឹង!!

កៈ ចា៎!!

ខ៖ មើលកើតថ្ងៃណាខែណាអីទៅយើងដឹងហើយ!!

ក៖ អញ្ចឹងអត់មានដឹងថ្ងៃខួបកំណើតខ្លួនឯងអីទេហោពូហោ?

ខ៖ អត់ទេ!!ហ៊ីអត់ដែលធ្វើខួបកំណើតម៉េចផង!!ដឹងតែថាកូនកើតមកចង់ធ្វើខួបកំណើតអោយកូនដឹងតែកូនហ្នឹងហ្ន៎បើយើងមិនធ្វើ!!

ក៖ ទាល់តែយកសំបុត្រកំណើត!!

ខ៖ បើយើងមិនធ្វើ!!

ក៖ ពូស្រុកភូមិពូកើតហាំ!!នៅភូមិឃុំអីគេដែរគេហៅ?

ខ៖ ញ៉ុមកើតនៅភូមិដំរីស្លាប់!!

ក៖ ហើយឃុំអីគេវិញទៀត?

ខ៖ ឃុំស្អាងភ្នំ ស្រុកស្អាងខេត្តកណ្តាលហ្នឹងម៉ង!!

ក៖ ចុះអាភូមិដំរីរស់នៅឯណាវិញ

ខ៖ អាភូមិដំរីរស់នៅណាអត់ដឹងដែរ គ្រាន់តែនៅត្រង់ហ្នឹងពីដើមកំណើតមកចាស់ៗគេហៅភូមិដំរីស្លាប់ ព្រោះដំរីវាស្លាប់នៅហ្នឹង!!

ក៖ ហ្នឹងហើយញ៉ុមគិតថាប្រហែលជាច្រើនហើយបានអញ្ចឹងហី?

ខ៖ បាទ!!

ក៖ ធម្មតាភាគច្រើនៅក្នុងស្រុកខ្មែរយើងអោយតែមានអ្វីមួយកើតឡើង ឬក៏មានអ្វីមួយដែលកើតឡើងអាធឹកអាចម្មអញ្ចឹងទៅណាស់!!

ខ៖ បាទ!!

ក៖ គេដាក់ភូមិហ្នឹងឈ្មោះអញ្ចឹងហើយ!!

ខ៖ ហ្នឹងហើយ។

កៈ ហ្នឹងហើយដូចនៅភូមិព្រៃកហូរអញ្ចឹងពេលមុនមិនស្រួលពេលមុនមានព្រៃកមានអីហូរអញ្ចឹងឬក៏មានដំនើររឿងអីមួយទៅបានគេដាក់អញ្ចឹង!!

ខៈ ប៉ុន្តែឥឡូវហ្នឹងទៅរកដំរីស្លាប់ហ្នឹងអត់ឃើញទេ រកភូមិថ្មី គេដាក់ភូមិថ្មី!!

កៈ ហ្នំ!!

ខៈ បានក្នុងឥឡូវហ្នឹង ប៉ុន្តែពីដើមកំនើតមកគេដាក់ភូមិហ្នឹងគេហៅថាភូមិដំរីស្លាប់!!

កៈ អញ្ចឹងគេដូរហើយពូណោះ?

ខៈ បាទគេដូរហើយគេដូរដាក់ភូមិថ្មី!!

កៈ ចាំ!!

ខៈ ហ្នឹងហើយ។

កៈ និយាយទៅដោយសារតែរដ្ឋបាលដែនដីហ្នឹងគេផ្លាស់ប្តូរច្រើនណាស់។

ខៈ ហ្នឹងហើយ។

កៈ ពេលមុននៅនេះអីវ៉ាន់សុទ្ធតែភូមិឃុំអីវ៉ាន់ទេ តែឥឡូវគេដូរដាក់សង្កាត់ដូរដាក់អីអស់ហើយហ្នឹង!!

ខៈ បាទ!!

កៈ គេពង្រីកក្រុងហ្នំពូ!!ចាំបាច់ដូរធ្វើអីទេ មិនព្រមរក្សាទៅអត់ទេ!!

ខៈ មិនដឹងទេ។

កៈ អោយអាពីដើមមកម៉េចអញ្ចឹងទៅណាស់!!កុំអោយបាត់ប្រវត្តិរកមិនឃើញ!!

ខៈ ហ្នឹងហើយ!!

កៈ លោកពូម្តាយរបស់លោកពូគាត់ឈ្មោះអីគេដែរ?

ខៈ ម្តាយខ្ញុំឈ្មោះឡុងសៀង។

កៈ ចាំគាត់នៅមានជីវិតរស់នៅសព្វថ្ងៃ!!

ខៈ បាទ!!

កៈ ចាំពូចាំថាគាត់អាយុប៉ុន្មានទេសព្វថ្ងៃហ្នឹង?

ខៈ អាយុប្រហែលជា៨០ជាងហើយម្ដាយរបស់ញ៉ុម!!

កៈ តែអត់ចាំ៨០ប៉ុន្មានទេពូហី?

ខៈ ប្រហែលជា៨០ជាង បើឪញ៉ុម៧០ជាងដែរ!!

កៈ ហា!អញ្ចឹងម៉ែបងប៉ា?

ខៈ ហ្នឹងហើយ។

កៈ បងប៉ាឡើង១០ឆ្នាំជាង?

ខៈ បាទ!!

កៈ ចាំឆ្នាំខ្មែរគាត់កើតសត្វអីគេពូម៉ែ?

ខៈ អត់ដឹងទេ!!

កៈ អត់ដឹងទេហោ?

ខៈ អត់ដឹង មកពីយើងមិនបានសួរនាំគាត់ផង!!

កៈ ចាំ!!

ខៈ តែញ៉ូមប៉ាន៎គាត់មើលប្រហែលជាអាយុប្រហែលជា៨០ជាងហ្នឹង។

កៈ ចាំហើយគាងត់អ្នកស្រុកមកពីណាវិញពូ?

ខៈ គាត់អ្នកស្រុកយើងមកពីស្រុកស្អាងហ្នឹងដែរហ្នឹង!!

កៈ ចាំ!!

ខ៖ ប៉ុន្តែគាត់គ្រាន់តែថានៅយើងម៉ុំព្រែកថ្មីយើងណោះ ព្រែកថ្មីក្បាលកោះ!!

ក៖ ហ្ន៎!!

ខ៖ ហួសព្រែកតូចយើងទៅបន្តិចទៅនេះ!!

ក៖ តែនៅស្អាងខេត្តកណ្តាលយើងដែរ!!

ខ៖ បាទនៅស្អាងខេត្តកណ្តាលហ្នឹងតែមួយ!!

ក៖ ចា៎!!អញ្ចឹងពូអើរតើម្តាយរបស់ពូតាំងពីពូនៅពីក្មេងហ្នឹងមក មកដល់ឥឡូវហ្នឹងអញ្ចឹងហា៎!! ដូចពូចាំថាគាត់គាត់រកស៊ីអីគេខ្លះដើម្បីចិញ្ចឹងគ្រួសារ?

ខ៖ គាត់រកជំនួញជួញដូរដូចជាបន្លែ លក់បន្លែ លក់ឪឡឹកអីចឹងទៅណាស់!!

ក៖ មានធ្វើស្រែធ្វើអីអត់ពូ?

ខ៖ ធ្វើតើ!!

ក៖ ធ្វើស្រែដែរហោ?

ខ៖ ហ្នឹងធ្វើស្រែ ធ្វើចំការដាំខ្លួនឯងខ្លះអីចឹងទៅ!!ទិញគេខ្លះ!!

ក៖ ចា៎!!អ្នកដែលនៅស្អាងភាគច្រើនគឺច្រើនតែអញ្ចឹង !!

ខ៖ បាទៗ!

ក៖ ច្រើនតែគាត់ដាំអីដាំបន្លែងញ្ចឹង ពូនៅពីក្មេងមកពូជួយដាំបន្លែដាំអីគាត់ដែរហោ?

ខ៖ ជួយតើ!!

ក៖ ដាំបន្លែអីគេខ្លះពូ?

ខ៖ ឆៃថាវ។

ក៖ ហូ!!

ខ៖ ហ្នឹងហើយ!!

ក៖ ពូអាឆៃថាវហ្នឹងបើគេព្រោះវាគេអត់ដកវាយកទៅបណ្តុះ?

ខ៖ អត់ទេ អត់ទេ!!

ក៖ អាហ្នឹងគេធ្វើម៉េចទៅ?

ខ៖ អាហ្នឹងគេនេះកូនម៉ង គេធ្វើរងហើយដាក់គ្រាប់យកទៅម៉ង ឧបមាថាយើងចាប់ទៅប៉ុន្មាន៦ ៧គ្រាប់ហ្នឹង យើងដឹងតែ៦ ៧គ្រាប់ ។

ក៖ ដុះមកម៉ង?

ខ៖ បាទ!!ដុះមកយើងចីរចោលទៅ។

ក៖ ហ្ហ៎!!

ខ៖ អាហ្នឹងយើងចីរកុនហ្នឹងយើងយកទៅធ្វើជ្រក់ធ្វើអីទៅ!!

ក៖ ចាំ!!

ខ៖ គេអត់យកទៅដាំទៀតទេ បើដាំទៀតម៉េចរស់!!

ក៖ ហ្ហ៎អាហ្នឹងដាំទៅត្រូវតែអាមើមហ្នឹងនៅហ្នឹងម៉ង អត់មានចីរយកទៅដាំនៅកន្លែងផ្សេងដើម្បីអោយមើមហ្នឹងធំទេហោ?

ខ៖ អត់ទេ !! ហ្នឹងហើយ!!បើខាត់ណាគេដាំផ្សេងអាហ្នឹងគេបណ្តុះកូនផ្សេងវិញ។

ក៖ ម៉េចវិញទៅ ខាត់ណាឈើហ្នឹងមែន?

ខ៖ ខាត់ណាឈើហ្នឹងគេបណ្តុះវា គេសាបវាចោលហើយបានគេដកវាយកទៅស្ទូង។

ក៖ ចាំ!!

ខ៖ អានេះបើឆៃថាវអត់ទេ យើងឧបមាថាយើង៦ ៧គ្រាប់អញ្ចឹងយើងឡើងទុកតែ៣គប់ទេ ក្នុងមួយជួរហ្នឹង!!

កៈ ហ៊ឺៗ!!

ខៈ យើងទុកតែពគប់ហ្នឹងបានវាមើមធំៗ

កៈ ហ្ហ៎!!

ខៈ ហើយបើយើងទុកទាំងអស់មើមប៉ុនៗមេជើងហ្នឹង!!ទូចៗវាចង្អៀតហា៎!!

កៈ ចា៎!!អ៊ីចឹងវាចុះមើមមិនកើត!!

ខៈ បាទ!!

កៈ ពូដីនៅស្អាងដាំអាបន្លែអ៊ីចឹងៗបានម៉ង ពូហេ?

ខៈ ដាំបានតើ!!ដូចជាអំពៅ ដូចជាប៊ិគក់អីវ៉ាន់ហ្នឹងណែនហ្នឹង!!ដាំល្អណាស់!!

កៈ ឥឡូវគេនៅធ្វើអ៊ីចឹងទៀត?

ខៈ នៅតើ!!នៅធ្វើតើ!!

កៈ ចា៎!!ពូនៅមានដីមានអីនៅហ្នឹងដែរតើហី?

ខៈ ញ៉ុមមានតើ!!

កៈ ហើយមានហើយមិនព្រមនៅធ្វើហ្នឹងហើយចាំបាច់មកធ្វើរកស៊ីស្រុកឆ្ងាយ?

ខៈ ទេ!!ញ៉ុមនិយាយអោយត្រង់ញ៉ុមទឹមតែមានប្រពន្ធហ្នឹង!!

កៈ ហ្ហ៎!!

ខៈ ៤ ៥ឆ្នាំហ្នឹង!!និយាយអោយត្រង់ម៉ង!!

កៈ ឆិតដូចបងស្រីដែរ!!

ខៈ ហ្នឹង!!

កៈ អត់យកប្រពន្ធ!!

ខ៖ ទឹមមាន៥ ឆ្នាំ ៥ ៦ឆ្នាំហ្នឹង!!

ក៖ អ៊ីចឹងពូពូអាយុ៤៣ហើយបានទឹមតែរៀបការពូណោះ?

ខ៖ បាទ!!

ក៖ តែពេលមុនមកអត់ធ្លាប់មានប្រពន្ធមុនទេហោ?

ខ៖ មាន មាន មានម្តងហើយ!!

ក៖ ហ្វូមានម្តងហើយដែរហោ?

ខ៖ បាទ!!

ក៖ អញ្ចឹងទឹមតែមកមានប្រពន្ធក្រោយទៀត!!

ខ៖ បាទ!!

ក៖ ពូចំនុចកន្លែងណាដែលស្រលាញ់ម៉ែជាងគេអញ្ចឹងហាំ?

ខ៖ ស្រលាញ់ម្តាយ?

ក៖ ចាំ!!

ខ៖ ស្រលាញ់ម្តាយយើងស្រលាញ់ហើយ ស្រលាញ់ត្រង់តែគាត់ថែរក្សាយើង។

ក៖ ចាំហ្នឹងហើយអញ្ចឹងគាត់ជាមនុស្សដែលមានចរិកម៉េចដែរមើលនិយាយគាត់បន្តិចមើល?

ខ៖ គាត់ចេះថែរក្សាយើង គាត់ចេះបីបាច់ថែរក្សាយើង មុជទឹកអោយយើង ចេះរៀបចំអោយយើងរៀនសូត្រ។

ក៖ ចាំ!!

ខ៖ អាហ្នឹងយើងស្រលាញ់គាត់ហើយ!!ម្តាយ!!

ក៖ ហ្នឹងហើយ ដូចជាចំនុចពិសេសដែលពូចងចាំជាមួយគាត់ភ្លេចមិនបានហាំចំនុចណាទៅ? ដូចជាគាត់ធ្វើអីល្អមួយសំរាប់ពូអញ្ចឹងហាំ??

ខ៖ គាត់ធ្វើល្អ ដូចពេលយើងឈឺអីអញ្ចឹងគាត់ខំមើលយើង ស្មុះស្មារអីមើលយើង អ៊ីចឹងយើងមិនអាចបំភ្លេចគុណគាត់បានទេអាហ្នឹង!

ក៖ ចាំហ្នឹងហើយ អ៊ីចឹងល្អណាស់អ៊ីចឹង!!ម៉ែ និយាយទៅទោះម៉ែម៉េចក៏ម៉ែល្អដែរមើលទៅម៉ែម៉េចក៏ដោយ!!!អញ្ចឹងពូសំរាប់ឪពុកវិញម្ដាយ ឪពុកលោកពូឈ្មោះអីគេវិញ?

ខ៖ ឪពុកញ៉ុមឈ្មោះ ចាន់ យ៉ែម។

ក៖ ចាន់ យ៉ែម?

ខ៖ បាទ!!

ក៖ ឥឡូវសព្វថ្ងៃគាត់អាយុប៉ុន្មានវិញលោកពូ?

ខ៖ គាត់ប្រហែលជា៧៥ហើយតាមមើល!!

ក៖ ពូចាំឆ្នាំខ្មែរគាត់កើតសត្វអីគេទេ?

ខ៖ អត់ដឹងដែរ។

ក៖ ចាំ ចាំគាត់កើតនៅថ្ងៃណាអត់ចាំដែរ?

ខ៖ អត់ទេ!!អត់ដែលសួរគាត់ផង!!

ក៖ ហ៊ឺ!!ដល់តែនៅក្នុងសំបុត្រកំណើតមានម៉ង?

ខ៖ មានម៉ង!!សំបុត្រកំនើតមានហើយដាក់កើតខែណាឆ្នាំណាអីគេមានហើយ!!ដឹងមានទាំងអស់បើយើងមិនមានសំបុត្រកំនើតហ្នឹងបោះឆ្នោតម៉េចកើត!!

ក៖ ចាំ!!អញ្ចឹងសំរាប់សព្វថ្ងៃហ្នឹង ឪពុក៧៥ឆ្នាំនៅក្នុងឆ្នាំ២០១៨?អញ្ចឹងដឹងហើយថាបើសិនជាអ្នកណាគេចង់ដឹងថ្ងៃខែឆ្នាំកំណើតរបស់គាត់ឆ្នាំពេលណាគាត់ដកទៅគាត់ដឹងហើយពូ!!

ខ៖ បាទ!!

ក៖ អ្នកស្រុកពុកលោកពូអ្នកស្រុកមកពីណាវិញពូ?

ខ៖ ស្រុកឪពុកញុំមនៅហ្នឹងដែរ។

ក៖ នៅដំរីស្លាប់ហ្នឹង។

ខ៖ បាទ!!

ក៖ ភូមិដំរីស្លាប់ឃុំអីគេលោកពូ?

ខ៖ ឃុំដំរីស្លាប់ ស្រុកស្អាង ខេត្តកណ្តាល។

ក៖ ចាំហ្នឹងហើយ!!អញ្ចឹងពូសំរាប់ឪពុកពូគាត់ធ្វើការអីគេដែរ ពូរៀបរាប់ការងារគាត់?

ខ៖ គាត់ក្នុងឥឡូវហើយពេលមុនមកគាត់ធ្វើការនិយាយអោយត្រង់ម៉ងគាត់កាប់គោ។

ក៖ ហ្វាំអ្នករកស៊ីកាប់គោ?

ខ៖ បាទ ប៉ុន្តែឥឡូវគាត់ចាស់ហើយគាត់រកអត់កើតទេ!!

ក៖ ចាំ!!

ខ៖ គាត់នៅឃ្វាលគោឃ្វាលអីដាំបន្លែងដាំអីនាយអាយអីហ្នឹង !!

ក៖ ហ៊ីៗ!!

ខ៖ លែងគោចោលអីហ្នឹងដើរមើលគោហ្នឹងហាំ!!

ក៖ ឥឡូវនៅតែមើលគោហ្នឹងពូហេ?

ខ៖ មើលតើ!!

ក៖ តែដាំបន្លែដាំអីទេ

ខ៖ ឥឡូវប្រហែលជាដាំ ដាំឪឡឹកនាយអាយអីតិចតួចហ្នឹង!!

ក៖ ចាំ!!

ខ៖ យើងមិនអាចយើងដាំធំដូចមុនបានទេណាស់!!

កៈ ពូ ពូភាគច្រើននៅជិតភ្នំស្ពាងមែននៅម្តុំពូនៅ?

ខៈ ញ៉ុមនៅម្តុំហួសភ្នំស្ពាងតិចទៀត!!

កៈ ហ្ហ៎!!!

ខៈ គេហៅស្ពាងស្រែហ្ហ៎!!

កៈ ចាំ!!

ខៈ វត្តស្ពាងស្រែហ្ហ៎!!

កៈ នៅជិតកោះធំទេពូ?

ខៈ ហេទៅទៅជិតអីកោះធំអីណោះវិញ!!

កៈ នៅជិតអាស្អីគេ?

ខៈ នៅនឹងអាយនេះហ្នឹង។

កៈ មិនមែននៅអាជិតទឹកពៅមួយកែវថៃមួយកែវទេនោះហេ?

ខៈ អត់ទេអាហ្នឹងទៅអាផ្លូវត្រង់ទេ ញ៉ុមទៅចូលអាវត្តស្ពាងភ្នំហ្នឹងម៉ង!!

កៈ ហ្ហ៎ហ្នឹងហើយ!!ហ្ហ៎ចូលផ្លូវលំចូលខាងក្រោយ។

ខៈ បាទហ្នឹងហើយ!!

កៈ ពូពេលពុកពូកាប់គោអីវ៉ាន់ពូដែលឃើញទេ?

ខៈ ថីមិនដែល។

កៈ ពូញ៉ុមឆ្ងល់ ញ៉ុមហូបតែសាច់គោអីវ៉ាន់មែនប៉ុន្តែញ៉ុមអត់ដឹងថាអាគេកាប់គោហ្នឹងម៉េចទេ គេច្រកថ្នាំអោយគោងាប់សិនឬក៏កាប់ទាំងរស់ម៉ង?

ខៈ អត់ទេ អារករម៉ង!!

កៈ កាប់ទាំងរស់ហ្នឹង?

ខៈ បាទ!!ចងជើងវាអារករ។

កៈ អូយ!!

ខៈ ទៅច្រកថ្នាំមិនពុលមនុស្សងាប់បាត់ហើយ!!

កៈ អូយ ញ៉ុមស្មានតែគេរបៀបដូចថាបើសិនជាវាកាប់គោទាំងស្រស់ទាំងស្រស់ពេកលោរវាដូចវាមានអារម្មណ៍ថាដូចវាដូចរាងគួរអោយខ្លាចណាស់ពូ សាហាវណាស់។

ខៈ អត់ទេគាត់អារករម៉េង ចងជើងវាផ្ដួល អារករយកម៉េង!!

កៈ អូយញ៉ុមអានិតណាស់!!

ខៈ តែដល់ពេលក្នុងឥឡូវយើងឆក់។

កៈ ឆក់សិនហោ?

ខៈ បាទឥឡូវហ្នឹងគេឆក់ហើយបានចាប់ផ្ដើមអាករ ឆក់អោយសន្លប់។

កៈ អញ្ចឹងទៅវាគ្រាន់បើតិចដែរពូណោះ តែអើយយ៉ាប់!!អានិតណាស់!!ញ៉ុមអត់ដែលសួរជីកឬសជីកគល់ពីអារឿងគោហ្នឹងទេពូ ដល់ពេលសួរអញ្ចឹងទៅមានអារម្មណ៍ថាហូបសាច់គោសាច់អីញ៉ុមអានិតវាណាស់!!តែធម្មតាសត្វហ្នឹងវាកើតមកជាម្ហូបរបស់មនុស្សហើយពូណាស់!!

ខៈ ហ្នឹង!!

កៈ ចាំ អញ្ចឹងពូអ្នកដែលភាគច្រើនអ្នកដែលកាប់គោអញ្ចឹងចំនេញច្រើនណាស់ពូហោ?

ខៈ អើរវាចំនេញ បើមិនចំនេញគេធ្វើធ្វើអី!!

កៈ ប៉ុន្ដែដោយសារអញ្ចេកពេលខ្លះចំនេញច្រើនពេលខ្លះចំនេញតិចអីអញ្ចឹងទៅណាស់!!

ខៈ វាចំនេញដែរ តែចំនេញតិចតួចៗហ្នឹង!!

កៈ ចាំ!!

ខ៖ វាមិនអាចនិយាយបានថាក្នុងគោមួយយើងទិញ១០០០០០០អញ្ចឹងយើងចំនេញ ១០០០០០០ទេ!!

ក៖ ហ្នឹងហើយ។

ខ៖ ៥០០០០ ១០០០០០ ២០០០០០ អីហ្នឹងអស់ហើយ!!

ក៖ ចាំតែគាត់ឈប់ធ្វើមួយហ្នឹងប៉ុន្មានឆ្នាំហើយពូ?

ខ៖ ហ្នំឈប់ធ្វើយូរហើយ ប្រហែលជា១៥ឆ្នាំហើយ។

ក៖ ហ្នំ!!

ខ៖ យូរហើយ គាត់ចាស់ហើយណាស់!!

ក៖ ចាំ!! ហ្នឹងហើយ ពូគិតថាធ្វើអញ្ចឹងមានបាបអីអត់?

ខ៖ មានអារម្មណ៍ថាបាបដូចតែគ្នាហ្នឹង តែគ្រាន់តែថាអានេះវារបស់មនុស្សវាត្រូវបំរើមនុស្សអញ្ចឹងម៉ង!!

ក៖ ចាំ!!

ខ៖ បើយើងមិនធ្វើវាមិនដាច់ពោះ!!

ក៖ ហ្នឹងហើយ!!

ខ៖ ខ្លួនយើង។

ក៖ តែញ៉ុមគិតថាមួយហ្នឹងហ្នំពូទោះតែដឹងថាអាគោកគោអីវ៉ាន់ ទោះអញ្ចឹងញ៉ុមគិតថាសំលាប់ដើម្បីម្ហូបអាហារមែនញ៉ុមគិតថាមួយហ្នឹងអត់បាបទេ អឺចឹងវាដោយសារដូចពូបាននិយាយ អឺចឹងដោយសារ ជាម្ហូបអាហារសំរាប់មនុស្សអឺចឹង តែបើសិនជាយកអារបស់សត្វហ្នឹងទៅលេងសើចអាហ្នឹងប្រហែលជាបាបវិញ!!

ខ៖ បាទ!!

កៈ ដោយសារយើងធ្វើដើម្បីសំរាប់តំរូវការរបស់មនុស្ស ដោយសារមនុស្សត្រូវតែមានសត្វដើម្បីយកមកចិញ្ចឹមខ្លួន ចិញ្ចឹមក្រពះអីវ៉ាន់អញ្ចឹង!!ត្រូវតែហូបបើមិនហូបវាមិនកើត ។

ខៈ ហ្នឹងហើយ។

កៈ យើងមិនអាចទៅស៊ីស្មៅហ្នឹងដូចគោបានផង ចាំហ្នឹងហើយ!!

ខៈ ហ្នឹងហើយ!!

កៈ ពូស្រលាញ់ឪពុកលោកពូឪពុកលោកពូគាត់គឺជាមនុស្សបែបម៉េចដែរ ស្រលាញ់គាត់បែបណា?

ខៈ ឪពុកញ៉ុមគាត់ជាមនុស្សល្អ គាត់ល្អគាត់ចេះថែរក្សាយើង។

កៈ ពីដើមមកគាត់ទូន្មានពូម៉េចដែរពូ?

ខៈ ទូន្មានអោយកូនធ្វើល្អអត់អោយកូនធ្វើអាក្រក់!!

កៈ ដែលដូចជាចរិកគាត់ដូចអត់សូវកាចអីណាពូហោ?

ខៈ អត់អីទេ ឪពុកញ៉ុមអត់កាចអីផង!!

កៈ ចាំ!!

ខៈ ឪពុកញ៉ុមទៅដល់ម៉ានគាត់គ្រាន់តែទៅដល់ម៉ានក៏ត្រូវតែមករក។

កៈ ចាំហ្នឹងហើយ!!ចុះកូនចៅមកពីណាច្រើនម្ល៉េះ?

ខៈ កូនគេ កូនញ៉ុមតែមួយនេះ(កូនតូចលោកពូដើរមក)។

កៈ ហ្ហំកូនមួយទៀតហោ?

ខៈ បាទ!!២នៅក្នុងពោះហ្នឹង!!

កៈ ចុះពីមុនមកពូមានកូនទៀតដែរតើហោ?

ខៈ មាន២។

កៈ ហ្ហ៎ឥឡូវនេះទៀតហេ?

ខៈ នេះ២។

កៈ សក់លាបពណ៌ទៀត សក់លាបពណ៌ហើចាំងថ្ងៃ!!

ខៈ អត់ទេកើតមកអញ្ចឹតឯម៉ង!!

កៈ ហ៊ឺ!!

ខៈ កើតមកអានេះលាបថ្នាំខ្មៅទេនេះ។

កៈ ហ្ហ៎!!

ខៈ សក់ក្រហមឆេះតែម្ដង។

កៈ តែពូសក់ឡើងខ្មៅក្រឹប ពូ?

ខៈ បាទ!!

កៈ សក់ពូមានលាបថ្នាំពណ៌ខ្មៅអីគេទេ?

ខៈ អត់ទេ ។

កៈ តែឡើងខ្មៅក្រឹបហើយអត់មានស្កូវអីមួយ។

ខៈ តាំងពីដើមមកអត់ដែលលាប់គ្រាន់តែអត់ដែលលាបខ្មៅផង។

កៈ អាយុ៨៨ឆ្នាំគួរតែស្កូវមួយៗហើយណាស់តែអត់សោះម៉ង។

ខៈ ស្កូវតើ!!វាមិនចេះអត់ទេ។

កៈ តែឃើញវាឡើងខ្មៅក្រឹបម៉ងហើយណាស់!!ពូស្គាល់ដូនតាទេ ចាំមើលសួរ ចង់សួរតាយាយខាងម្ដាយហាំ?

ខៈ តា!!

កៈ តាឈ្មោះអីគេវិញ?

ខៈ តាឡុង!!

កៈ ចាំត្រកូលគាត់ទេ?

ខៈ ហេអត់ស្គាល់ដែរ តែស្គាល់ឪម្តាយញ៉ុមទៀតអាហ្នឹងនេះតាឡុង។

កៈ ចាំ!!

ខៈ ហ្នឹងហើយនឹងម្តាយឈ្មោះអីគេទេនេះ!!ញ៉ុមភ្លេចដែរហើយបើបើខាងឪអាហ្នឹងចាំ។

កៈ ឥឡូវឈប់និយាយខាងម៉ែសិន ម៉េចតាឈ្មោះតាឡុងហោ?

ខៈ បាទ!!

កៈ ឪរបស់ម្តាយរបស់ពូ?

ខៈ បាទ!!

កៈ ឈ្មោះតាឡុង។ប៉ុន្តែអត់ចាំត្រកូលរបស់គាត់ទេ?

ខៈ អត់ចាំទេ។

កៈ ពូកើតទាន់តាទេ?

ខៈ អត់ ។

កៈ ហើយម៉ែមានដែលប្រាប់ថាតាអីម៉េចៗអីអត់ពូ?

ខៈ អត់ផងអត់ប្រាប់ផង។

កៈ អត់ទាន់ហោ?

ខៈ ហ្នឹងហើយ បើយើងកើតមកអត់ដឹងតានៅឯណាផង!!

កៈ ស្លាប់ចោលអស់រលីងហើយ?

ខ៖ បាទ ស្លាប់ចោលតាំងពីជំនាន់ណាមកយើងអត់ដឹងដែរ!!

ក៖ ហ្នឹងហើយ អ៊ិចឹងពូសំរាប់យាយវិញយាយឈ្មោះអីគេវិញ?

ខ៖ យាយអើរយាយខាង!!

ក៖ ម៉ែ!!

ខ៖ ខាងម្ដាយហ្នឹង?

ក៖ ចាំ!!

ខ៖ អត់ស្គាល់។

ក៖ អា?? ម៉េចអត់ស្គាល់ឈ្មោះយាយអ៊ិចឹង?

ខ៖ អត់ស្គាល់ឈ្មោះ ស្គាល់ឈ្មោះតែតា។

ក៖ កើតមកយាយស្លាប់ដែរពូហេ?

ខ៖ ហ្នឹង!!

ក៖ យូរហើយពូហេ?

ខ៖ យាយហ្នឹងស្លាប់មុនតាទៀតហ្ន៎!!

ក៖ ហ្ន៎!!គិតថាគាត់ស្លាប់មុនសង្គ្រាមឬក៏យ៉ាងម៉េចដែរពូ?

ខ៖ មុនសង្គ្រាមទៀត!!

ក៖ ហ្ន៎ហ្នឹងហើយដោយសារ!!

ខ៖ ប្រហែលជាជំនាន់លន់ នល់ លន់អីណោះ!!

ក៖ ចាំ!!

ខ៖ ជំនាន់លន់ នល់អីហ្ន៎!!

កៈ ហ្នឹងហើយ ដោយសារពូកើតមកមុនសង្គ្រាមដែរហើយហ្នឹង!!

ខៈ បាទញ៉ុមកើតមកមុនជំនាន់អាពតទៀត។

កៈ ចាំហ្នឹងហើយ!!

ខៈ ជំនាន់អាពតញ៉ុមចូលធ្វើការដែរកាលហ្នឹង ដើរលើកអាចមន៍គោលើកអីហ្នឹង!!

កៈ ចាំហ្នឹងហើយ!!ចាំបន្តិចទៀតនិយាយរឿងមួយហ្នឹង!!ឥឡូវចូលដល់ជីដូនជីតាខាងនេះវិញ ម្ដងឪពុករបស់លោកពូតើតាឈ្មោះតាអីគេវិញ?

ខៈ តាឈ្មោះតាចាន់។

កៈ ចាំហើយចាំត្រកូលគាត់ទេ?

ខៈ អត់ទេហ្នឹង!!ហើយបើ!!

កៈ យាយ!!

ខៈ យាយយាយឈ្មោះយាយជា។

កៈ យាយជា អត់ចាំត្រកូលដែរ?

ខៈ បាទ!!

កៈ ពូកើតទាន់តាយាយទាំង២នាក់អត់?

ខៈ អត់ ប៉ុន្តែគ្រាន់តែគាត់បានប្រាប់រឿងតា!!

កៈ មើលប្រាប់ខ្លះម៉េចដែរ?

ខៈ ហ្នឹងហើយ!!

កៈ ថាតាម៉េចដែរតាគាត់ម៉េចដែរហ្នឹងហាំ!!ប្រវត្តិម៉េចដែរអ៊ីចឹងហាំ?

ខៈ ប្រវត្តិរបស់តារកស៊ីធំៗដែរហ្នឹងហាំ!!

កៈ ធ្វើអីគេវិញ?

ខៈ គាត់ពីដើមកំនើតមកគាត់ធ្វើការប៉ុន្តែមិនដឹងជាធ្វើការស្អី វាអត់ យើងអត់ដឹងដែរ។

កៈ គ្រាន់តែនៅក្នុងជួរអើរខាងការងាររាជការអ៊ីចឹងហេ?

ខៈ ហ្នឹងហើយគាត់ខាងធ្វើ ការងារហ្នឹង ការងារខាងរាជការអីហ្នឹងប៉ុន្តែមិនដឹងថាធ្វើខាងអី!!

កៈ តាអ្នកនៅទីណាវិញយាយពូស្រុកហាំ?

ខៈ ស្រុកអត់ដឹងទេប៉ុន្តែគ្រាន់តែថាញ៉ុមដឹងតែថាផ្ទះល្វែងគាត់នៅហ្នឹងទន្លេហ្នឹងនៅហ្នឹងនៅក្បាលកោះហ្នឹងម៉ង!!

កៈ ហ្អ៊ំ!!

ខៈ ក្បាលកោះនៅក្រោមព្រែកតូចនេះបន្តិចហ្នឹង ជាប់ផ្ទះអាកុយហ្នឹង អាកុយអ្នកកំប្លែងហ្នឹង។

កៈ ហ្នឹងហើយញ៉ុមឮថាតាកុយនៅខាងហ្នឹងដែរ!!

ខៈ ហ្នឹងហើយ!!

កៈ ហើយយាយ យាយអ្នកស្រុកមកពីណាវិញពូ?

ខៈ យាយនៅស្រុកទួលក្ងួញ។

កៈ ទួលក្ងួញហ្នឹងនៅឯណាវិញពូ?

ខៈ ទួលក្ងួញចុះមកពី ហុីស្រុកហ្នឹងជាមួយគ្នាហ្នឹងប៉ុន្តែគ្រាន់តែថាមួយស្រុករាងខុសគ្នាអ៊ីចឹងទៅណាស់!!

កៈ ចាំ!!

ខៈ ទួលក្ងួញ គេហៅភូមិទួលក្ងួញអ៊ីចឹងម៉ងៗ!!!

កៈ នៅស្រុកស្អាងហ្នឹងដែរ?

ខៈ នៅស្រុកស្អាងតែមួយហ្នឹង។

កៈ ចាំ!!ពូកើតទាន់យាយដែរអត់?

ខៈ អត់ទេ!!

កៈ អត់ដែរ?

ខៈ ចាំ!!

កៈ អញ្ចឹងតាយាយទាំងសងខាងពូកើតអត់ទាន់ម៉ង?

ខៈ អត់ទាន់ម៉ង ហ្នឹងមិនដឹងគាត់ស្លាប់តាំងពីរាជណាផង!!

កៈ ហ្ហ៎!!!ហើយឪពុកម្ដាយអត់ដែលប្រាប់ដែរពូហោ?

ខៈ អត់ទេ!!

កៈ ទៅបាត់ប្រវត្តិឈឹងអស់រលីងតែម្ដងអ៊ីចឹងទៅ!!ហើយចុះមិញភ្លេចសួរតាយាយខាងម្ដាយវិញគាត់នៅស្រុកណាវិញពូ?

ខៈ យាយខាងម្ដាយ?

កៈ ចាំ!!

ខៈ យាយខាងម្ដាយនៅស្រុកយើងស្រុកស្អាងហ្នឹងតែម្ដង។

កៈ តាក៏នៅហ្នឹងដែរ?

ខៈ នៅហ្នឹងដែរហ្នឹងប៉ុន្តែគ្រាន់តែថាភូមិឃុំវាខុសគ្នា!!

កៈ ចាំ!!

ខៈ ដូចភូមិយើងព្រែកហូរលិចព្រែកហូរកើតអ៊ីចឹងណាស់!!

កៈ ហ្ហ៎ភូមិទូចៗដែរ អ៊ីចឹងស្គាល់គ្នា!!

ខៈ បាទភូមិទូចៗហ្នឹងៗៗ។

កៈ ពូសំរាប់បងប្អូនរបស់ពូហាទាំងបងប្អូនជីដូនមួយឬមួយក៏បងប្អូនបង្កើតមានដែលអ្នកណាគេរស់នៅប្រទេសខាងក្រៅអីអត់?

ខៈ មានតែនៅថៃ។

កៈ ទៅធ្វើការមែនពូ?

ខៈ ហ្នឹងទៅធ្វើការនៅថៃ។

កៈ បងប្អូនខាងណាវិញ?

ខៈ អាហ្នឹងក្មួយម៉ងមិនមែនបងប្អូនទេ ក្មួយ ក្មួយ។

កៈ ចាំ!!

ខៈ ក្មួយប្រសារហាំ!!

កៈ ចាំ!!

ខៈ ហ្នឹងធ្វើការនៅហ្នឹងថៃខ្លះនៅបាត់ដំបងអីអញ្ចឹងទៅណាស់!!

កៈ ចាំ ពូចឺបានអត់ទៅធ្វើការនៅប្រទេសថៃហ្នឹងគេដែរ?

ខៈ ញ៉ុមទៅដែរប៉ុន្តែទៅអត់កើត។

កៈ គេត្រូវការប៉ាស់ស្ពរ័អីហ្នឹងពូហេ?

ខៈ ហ៊ីញ៉ុមទៅតាំងពីគេអត់ទាន់យកប៉ាស់ស្ព័រហ្ន៎!!ទៅធ្វើធ្វើការដែរ តែវាមិនជៀសជាងយើងធ្វើការរកស៊ីនៅក្នុងស្រុកខ្មែរយើងផង។

កៈ ចាំ!!

ខៈ មួយថ្ងៃ៣០០ ៤០០បាតក៏យើងរកនៅណោះបាន៣០០០០ ៤០០០០ ៥០០០០ដូចតែគ្នាហ្នឹង។

កៈ ហ្ន៎អ៊ីចឹងរកស៊ីនៅស្រុកខ្លួនឯងទៅ គ្រាន់បើជាង!!

ខ៖ ញ៉ុមទៅដែរទៅពីរនាក់ប្តីប្រពន្ធញ៉ុមហ្នឹងកាលកំណើតមីហ្នឹង!!

ក៖ ហ្អ៎!!

ខ៖ មីមួយទូចមិញ!!

ក៖ ពូទៅធ្វើការនៅស្រុកថៃធ្វើការអីគេវិញ?

ខ៖ ធ្វើសំនង់ ខាងសាងសង់ សាងសង់ហ្នឹងម៉ង!!

ក៖ ញ៉ុមឮថានៅស្រុកថៃអើរទោះធ្វើសំនង់អី និយាយថាប្រាក់ខែគឺស្មើគ្នាទាំងអស់ពូហោ?

ខ៖ ទេមានគេជាងអ៊ីចឹងទៅ មាន២០០អ៊ីចឹងទៅមានកម្មករ២៥០អីអញ្ចឹងទៅណាស់!!

ក៖ ចា៎!!

ខ៖ ហ្នឹងមានអាខ្លះគេ គេការងារគេចំណាប់អ៊ីចឹងទៅមានន៣០០អ៊ីចឹងទៅណាស់!!

ក៖ ចា៎អ៊ីចឹងវាតាមហ្នឹង។

ខ៖ មិនមែនប្រាក់ខែស្មើៗគ្នាទាំងអស់គ្នាអត់ទេ!!

ក៖ ចា៎!!

ខ៖ ហ្នឹងឧបមាថាអាហ្នឹងគេសាងសង់ទេណាស់!!

ក៖ ហ៊ីៗ!!

ខ៖ បើរឿងខាងមាន់អីគេគេចិញ្ចឹមមាន់ចិញ្ចឹមអីញ៉ុមអត់ដឹងដែរ!!

ក៖ ចា៎!!

ខ៖ ព្រោះយើងវាមិនដែលចូលធ្វើអាខាងកសិកម្មហ្នឹងហា៎!!

ក៖ ចា៎!!ពូហ្នឹង ទៅតាមរយៈអ្នកណាគេដែរ?

ខ៖ ក្មួយយកទៅម៉ង។

កះ ពេលធ្វើហ្នឹងនៅខេត្តអីគេដែរពូ នៅប្រទេសថៃ?

ខះ នៅប្រទេសថៃនៅស្អីគេទេ រ៉ាក់យ៉ោង!!

កះ ហ្ហ៎ញ៉ុមទឹមទៅពេលមុនដែរ!!

ខះ មើលនៅស្អីទេ !!នៅជាប់អណ្ដូងប្រេងកាតនោះ។

កះ អត់ស្គាល់ផង!!

ខះ នៅទីក្រុងម៉ងហា៎!!

កះ បាងកកហេ?

ខះ មិនមែនបាងកកទេ!!

កះ ឈៀងរ៉ៃ?

ខះ នៅស្អីគេទេ!!នៅពីអណ្ដូងប្រេងកាតហើយនៅមើលឃើញអញ្ចឹង!!

កះ ហ្ហ៎!!គេខួងអណ្ដូងប្រេងកាតនៅហ្នឹងដែរពូហេ?

ខះ បាទ!

កះ ញ៉ុមទៅហ្នឹង អីគេ នៅរ៉ាក់យ៉ោងថ្ងៃមុនដែរនៅជិតសមុទ្រ ពូធ្វើការនៅជិតសមុទ្រទេ?

ខះ ហ្នឹងជាប់សមុទ្រហ្នឹងម៉ង!!

កះ អ៊ិចឹងមានតែនៅហ្នឹងហើយអ៊ីចឹង។

ខះ មើលទៅឃើញសមុទ្រច្បាស់ថៃស។

កះ ហ្ហ៎ដល់ពេលមានអារម្មណ៍ថាអស់កំលាំងអស់អីទៅ ដើរទៅសមុទ្រលេងដែរទៅ!!

ខះ អើរនៅហ្នឹងប្រហែល២ខែដែរញ៉ុមមកវិញ ដូចមើលទៅវាមិនកើត។

កះ ចា៎វាមិនស្រួលដូចនៅស្រុកខ្មែរ!!

ខ៖ វាមិនកើតអីគេដេញម៉ងហ្នឹង គេដេញចាប់ម៉ងហ្នឹងអ៊ីចឹង និយាយទៅម៉ងទៅ!!

ក៖ ហ្អ៎!!

ខ៖ កាលយើងទៅអត់មានបណ្ណ័ អត់គេអត់សារវើអាប៉ាស់ស្ព័រហ្នឹង។

ក៖ ចា៎!!!

ខ៖ គេមិននេះថៅកែដឹកយើងយកទៅលាក់យកទៅអីក៏វាពិបាកដែរ!!

ក៖ ហ្នឹងហើយ។

ខ៖ ហ្នឹងថៅកែដឹកយើងយកទៅលាក់តើ!!

ក៖ អូយ!!

ខ៖ ប៉ុន្តែយើងលាក់យើងពិបាក អាណាមួយខែធ្វើបានតែ៣ ៤ ៥ថ្ងៃ!!

ក៖ លាក់រហូត?

ខ៖ បាទ!!លាក់ ពិបាកដែរខ្ចិលមកផ្ទះម៉ងទៅ!!

ក៖ ចា៎!!ទោះម៉េចក៏មានអីអត់មានអីនៅផ្ទះយើងស្រួលជាងពូហេ?

ខ៖ បាទ!!

ក៖ ហ្នឹងហើយ ពូពេលដែលជីវិតពូដែលពិបាកបំផុតនៅឯណាវិញទៅ?ពេលណាដែលពូគិតថាជីវិតពូពិបាកជាងគេអញ្ចឹងទៅណាស់?

ខ៖ ពិបាក?

ក៖ ចា៎!!

ខ៖ ញ៉ុមអត់មានពេលណាដែលពិបាកអីផងគិតតែខំរកស៊ីហ្នឹងម៉ង!!

ក៖ ដឹងតែពីជីវិត ខំរកស៊ីម៉ង?

ខ៖ បាទដឹងតែជីវិតខំប្រឹងខ្លាចតែវាអត់។

ក៖ ហ្នឹងហើយ!!

ខ៖ វាពិបាកហាត់អីអញ្ចឹងទៅ!!

ក៖ អ៊ីចឹងជីវិតពុះពារច្រើនខ្លាំងណាស់អ៊ីចឹងណាស់ពូណេះ?

ខ៖ ហ្នឹងហើយចេះតែខំរកស៊ីអញ្ចឹងទៅ!!ដើម្បីកូន។

ក៖ អូខេអញ្ចឹងអរគុណច្រើនលោកពូដែលអោយញ៉ុមសំភាសន៍អំពីជីវិតលោកពូ កូនចៅរបស់លោកពូគាត់នឹងបានស្តាប់អំពីជីវិតរបស់លោកពូពេលទៅថ្ងៃក្រោយទៅ៕